# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1067

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : គម្រោងអភិរក្ស និងលើកតម្លៃរចនាសម្ព័ន្ធប្រាសាទនៅក្នុងឧទ្យានអង្គរ

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/01/26

កាលបរិច្ឆេទបញ្ចប់គម្រោង 31/12/28

៣. ចំណាយគម្រោងសរុប $4,600,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

RESPONSIBLE UNIT APSARA National Authority

អង្គភាពទទួលខុសត្រូវ អាជ្ញាធរជាតិអប្សរា

៥. ស្ថានភាពគម្រោង គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ស្វែងរកម្ចាស់ជំនួយ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី២- ការគ្រប់គ្រងធនធានធម្មជាតិ, បេតិកភណ្ឌវប្បធម៌ និងទេសចរណ៍ ប្រកបដោយចីរភាព

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

ចូលរួមថែរក្សា និងអភិរក្ស និងលើកតម្លៃបេតិកភណ្ឌក្នុងតំបន់អង្គរឱ្យគង់វង្ស និងផ្តល់ចំណេះដឹង និងបទពិសោធន៍។

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

វប្បធម៌ និងសិល្បៈ Culture and Fine Arts

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

សៀមរាប,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គម្រោងនេះមានគោលបំណង ដើម្បីសង្គ្រោះប្រាសាទពីស្ថានភាពគ្រោះថ្នាក់ ស្រាវជ្រាវចងក្រងឯកសារសម្រាប់អ្នកជំនាន់ក្រោយក្នុងការថែរក្សា និងអភិរក្ស លើកតម្លៃបេតិកភណ្ឌជាតិ និងបម្រើវិស័យទេសចរណ៍។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

ប្រាសាទចំនួន១០ ដូចបានរាយឈ្មោះខាងក្រោមមានទីតាំងចំនួន១៨កំពុងប្រឈមកម្រិតហានិភ័យខ្លាំង ក្នុងនោះសម្ភារសំណង់ប្រាសាទមួយចំនួនបានបាត់បង់ ថ្មបែកបាក់ទ្រង់ទ្រាយ ពុកផុយ ដោយសារកត្តាអាយុកាល សង្គ្រាមស៊ីវិល កង្វះការថែទាំ និងធម្មជាតិ។ ហេតុនេះដើម្បីសង្គ្រោះប្រាសាទ ឱ្យរួចផុតពីស្ថានភាពគ្រោះថ្នាក់ ក្រុមការងារមានផែនការរៀបចំធ្វើការអភិរក្ស និងជួលជុលរចនាសម្ព័ន្ធប្រាសាទចំនួន ១៨ទីតាំងខាងលើឡើងវិញដូចខាងក្រោម ដើម្បីកាត់បន្ថយអាយុកាលនៃការខូចខាតសំណង់ប្រាសាទនិងរក្សាមរតកបេតិកភណ្ឌសម្រាប់មនុស្សជាតិទៅអនាគតៈ ក្នុងឧទ្យានអង្គរ ដែលជារមណីយដ្ឋាននៃបេតិកភណ្ឌពិភពលោក

១- ជួសជុលបណ្ណាល័យនិងប៉មកណ្តាលប្រាសាទសំរែ
២- ជួសជុលនិងពង្រឹងនៅប្រាសាទប្រែរូប (ក្លោងទ្វារខាងកើតខាងត្បូង,ប៉មលេខ៣,៤,៨,១២,១៣)
៣- ជួសជុលរួតកំពូលប៉មខាងត្បូងប្រា.បាតជុំទំហំ(ដំណា_ទី៦)
៤- ជួសជុលពង្រឹងសសរស្តម្ភចំនួន៧ បង្គោលសីម៉ា ១ ប្រា. បន្ទាយស្រី
៥- ជួសជុលបណ្ណាល័យអាគ្នេយ៍ប៉ែកខាងត្បូងប្រា.បាគង(ដំណា_ទី១)
៦- ជួសជុលចម្លាក់ដំរីចំនួន២ ចម្លាក់គោ៤ ប្រា.បាគង
៧- ជួសជុលច្រាំងកសិន្ទខាងលិចខាងជើង២០មប្រាសាទអង្គរវត្ត(ដំណា_ទី៥)
៨- ជួសជុលប៉មឥដ្ឋលេខ៤ប្រាសាទបាគង
៩- ជួសជុលស្រះទឹកខាងជើងប្រាសាទអង្គរវត្ត៤០ម៉ែត្រ(ដំណា_ទី៥)
១០-ជួសជុលប៉មឥដ្ឋ ប្រាសាទគោកពោធិ៍(ដំណា_ទី១)
១១- ជួសជុលប្រាសាទឃ្លាំងត្បូង(ដំណា_ទី១)
១២- ជួសជុលប៉មកណ្តាលនិងកម្រាល ប្រាសាទព្រៃមន្ទីរ(ដំណា.ទី២)
១៣-ជួសជុលប្រាសាទជ្រុងឥសាននៃកំពែងអង្គរធំ (ដំណា_ទី១)

១-ការងារជួសជុលប្រាសាទ ៖

- ស្រាវជ្រាវនិងចងក្រងឯកសារទាក់ទងនឹងប្រវត្តិអភិរក្សប្រាសាទកន្លងមក សម្រាប់ជាឯកសារគោលក្នុងការជួសជុលប្រាសាទ។
- ចុះបញ្ជីវត្ថុសិល្បៈ។
- សិក្សាប្លង់ឡើងវិញមុននឹងធ្វើការជួសជុល
- ធ្វើកំណាយស្រាវជ្រាវអំពីរចនាសម្ព័ន្ធរបស់ប្រាសាទ
- សិក្សាស្ថានភាពដីគ្រឹះមុននឹងធ្វើការជួសជុល។
- រៀបចំធ្វើរោងការដ្ឋាន
- សិក្សានិងស្វែងរកថ្ម
- ជួសជុល ត និងព្យាបាលថ្ម
- ផ្គុំគ្រឿងបង្គុំប្រាសាទសាកល្បងដើម្បីរៀបឡើងវិញ
- ចំណាយលើសម្ភារៈសំណង់ថ្មីមួយចំនួនសម្រាប់ធ្វើការងារជួសជុល មានដូចជា ថ្មភក់ ថ្មបាយក្រៀម ដីខ្សាច់និងសម្ភារៈចាំបាច់មួយចំនួនផ្សេងៗទៀត។ល។
- បញ្ចប់ការដ្ឋាន សំអាត, ធ្វើរបាយការណ៍ និងចងក្រងឯកសារ ព្រមទាំងបើកឲ្យទស្សនាឡើងវិញ។

២-ទល់ទ្រប្រាសាទ ៖
- សិក្សាពីហានិភ័យប្រាសាទដែលប្រឈមនឹងគ្រោះថ្នាក់
- លើកគម្រោងទល់ទ្រ និងសង្គ្រោះបន្ទាន់ ដើម្បីបញ្ចៀសគ្រោះថ្នាក់ដាយថាហេតុ។
- ចំណាយលើសម្ភារៈសំណង់មួយ( ឈើ ដែក លោហៈ ) សម្រាប់ការងារទល់ទ្រ និងសង្គ្រោះបន្ទាន់។
- បញ្ចប់ការដ្ឋាន សំអាត, ធ្វើរបាយការណ៍ និងចងក្រងឯកសារ និងបើកអោយទស្សនាឡើងវិញ។

៣-កំណាយស្រាវជ្រាវបុរាណវិទ្យា ៖
- សិក្សានិងធ្វើផែនទីឋានលេខា ដើម្បីរៀបចំប្លង់បច្ចេកទេស
- ធ្វើកំណាយស្រាវជ្រាវសិក្សាស្វែងយល់អំពីរចនាសម្ព័ន្ធបុរាណ វិភាគវត្ថុសិល្បៈដែលទទួលបាលពីការកំណាយ
- ចងក្រងទិន្នន័យបុរាណវិទ្យាទុកជាឯកសារ និង បោះពុម្ពផ្សព្វផ្សាយ។

៤- គ្រប់គ្រងនិងជួសជុលសមុច្ច័យ៖
- ធ្វើស្ថិតិ វិភាគ ជួសជុលវត្ថុសិល្បៈដែលបានពីកំណាយស្រាវជ្រាវ ។
- ចុះបញ្ជីបុរាណវត្ថុដែលរាយប៉ាយតាមប្រាសាទ

**១៥. យុត្តិកម្មលើគម្រោង** (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

**ការជ្រើសរើសគម្រោងនេះឡើង ក្នុងបំណងដើម្បីសង្គ្រោះបេតិកភណ្ឌអន្តរជាតិអោយរួចផុតពីស្ថានភាពគ្រោះថ្នាក់ រក្សាពីអត្តសញ្ញាណប្រវត្តិសាស្ត្រ ស្នារដៃសិល្បៈ និងធ្វើអោយមានភាពទាក់ទាញ សម្រាប់បម្រើអោយវិស័យទេសចរណ៍។**

**១៦. ផលប្រយោជន៍របស់គម្រោង** (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

**រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋក្នុងតំបន់សៀមរាបអង្គរ**

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **ត្រូវបានរៀបចំ**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**មិនប៉ះពាល់ដល់បរិស្ថាន និងសង្គមទេ**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
| --- | --- | --- |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការបង្ការ**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងនេះមិនប៉ះពាល់ដល់តួនាទីរបស់បុរស និងស្ត្រីទេ**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**អាជ្ញធរអប្សរាមានមន្ត្រីបច្ចេកទេស ដែលមានសមត្ថភាព បទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងនេះ។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

19

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**មិនទាន់មាន**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 715.0 | 719.0 | 726.0 | 2,160.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 715.0 | 719.0 | 726.0 | 2,160.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 805.0 | 811.0 | 824.0 | 2,440.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 805.0 | 811.0 | 824.0 | 2,440.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 1,520.0 | 1,530.0 | 1,550.0 | 4,600.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 1,520.0 | 1,530.0 | 1,550.0 | 4,600.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: